# ដំណោះស្រាយ យោធា ?

## ជា ជំនះបញ្ហា (défi) របស់ សាធារណរដ្ឋខ្មែរ



Lê Dú'c Tho et Henry Kissinger

**សរសេរ ដោយ ឧប សៅ សង្ហា**

គ្មានរក្សាសិទ្ធិ

# ដំណោះស្រាយ យោធា ?

## មាតិការឿង


សេចក្ដីផ្ដើម ........ 3

ដំណោះស្រាយ តាម ផ្លូវយោធា ? ........ 6

កម្លាំង កងទ័ព យៀកកុង និង យួនខាងជើង ........ 13

យុទ្ធសាស្ត្រយោធា នៃ សាធារណរដ្ឋខ្មែរ ........ 17

សង្គ្រាមចិត្តសាស្ត្រ និង មនោគមវិជ្ជា ........ 20

គោលជំហរ របស់ សហរដ្ឋអាមេរិក ........ 24

# ជំនោរក្រោយយោធា ?

## សេចក្ដីផ្ដើម

រយះពេល ២ ឆ្នាំ កន្លងមកហើយ ដែល ស្រុកខ្មែរ ប្រឈរមុខ នឹង ការវាយប្រហារ យ៉ាងសាហាវ ពីសំណាក់ កងទ័ព យួន កុម្មុយនិស្ត[1] គឺ រាប់ ពី ថ្ងៃ ទី ១៨ មីនា ឆ្នាំ ១៩៧០ មកដល់ថ្ងៃ ទី ៤ មិថុនា ឆ្នាំ ១៩៧២, ថ្ងៃ ដែល លោក លន់ នល់ ត្រូវបាន ប្រជាពលរដ្ឋ ជ្រើសតាំងលោក ជា ប្រធានាធិបតី នៃ សាធារណរដ្ឋខ្មែរ តាម ការបោះឆ្នោត សាកល ស្របនឹងច្បាប់ រដ្ឋធម្មនុញ្ញថ្មី, ហើយ របបនេះ ត្រូវបាន មហាសន្និបាត នៃ អ.ស.ប.[2] បោះឆ្នោត នៅថ្ងៃ ទី១២ តុលា ឆ្នាំ ១៩៧២ ទទួលស្គាល់ ជា ផ្លូវការ ថា ជា តំណាង នៃ ប្រជាពលរដ្ឋខ្មែរ ពិតប្រាកដ។ កងទ័ព យួន កុម្មុយនិស្ត ផ្ដើម វាយ កងទ័ពជាតិខ្មែរ ពី ថ្ងៃទី ២៩ មីនា ឆ្នាំ ១៩៧០ ដោយគ្មាន ប្រកាស ទុកជាមុន នៅក្នុង ភូមិភាគយោធា[3] :

---

[1] កងទ័ពនោះ មាន កងទ័ព យៀកកុង និង យួនខាងជើង គឺ យួនកុម្មុយនិស្ត។
[2] អ.ស.ប. : អង្គការ សហ ប្រជាជាតិ។
[3] លេខ១ : ការពារខេត្ត កំពង់ចាម, ព្រៃវែង, ស្វាយរៀង និង កណ្ដាល។ មាន ទីបញ្ជាការសឹក នៅ ទីក្រុង កំពង់ចាម។
លេខ២ : ការពារខេត្ត កំពង់ស្ពឺ, កំពត, តាកែវ, កំពង់សោម និង កោះកុង។ មាន ទីបញ្ជាការសឹក នៅ ទីក្រុង កំពង់ស្ពឺ។
លេខ៣ : ការពារខេត្ត បាត់ដំបង, កំពង់ឆ្នាំង និង ពោធិសាត់។ មាន ទីបញ្ជាការសឹក នៅ ទីក្រុង បាត់ដំបង។
លេខ៤ : ការពារខេត្ត សៀមរាប, កំពង់ធំ និង ព្រះវិហារ។ មាន ទីបញ្ជាការសឹក នៅ ទីក្រុង សៀមរាប។
លេខ៥ : ការពារខេត្ត ស្ទឹងត្រែង, និង រតនគីរី។ មាន ទីបញ្ជាការសឹក នៅ ទីក្រុង ស្ទឹងត្រែង។

## ដំណោះស្រាយ យោធា ?

លេខ១ : ស្រុក ស្នួល, ជប់, មីមុត, ក្រែក, ស្អាង និង កោះធំ,

លេខ២ : ស្រុក កំពង់ត្រាច,

លេខ៥ : ទីក្រុង ស្ទឹងត្រែង,

លេខ៦ : ទីក្រុង ក្រចេះ។

ដោយមាន ការសមគំនិត ពី សម្ដេច សីហនុ, កងទ័ពនោះ បាន ចូល មកបោះទ័ព នៅ ស្រុកខ្មែរ ចាប់តាំង ពី ឆ្នាំ ១៩៦២ ក្នុង ខេត្ត ស្ទឹងត្រែង, រតនគិរី, ក្រចេះ, ព្រៃវែង, តាកែវ និង កំពត, មាន ចំនួន យោធា និង បុគ្គលិក ស៊ីវិល ប្រមាណ ៦ ម៉ឺន នាក់។ រីឯ កងទ័ពជាតិខ្មែរ ទាំងបីកងទ័ព ជើងគោក, ជើងអាកាស និង ជើងទឹក មាន ចំនួន យោធា ប្រមាណ ៣ ម៉ឺន នាក់[4]។ តុល្យភាព កម្លាំង ខុសគ្នានោះឯង ដែល អាចឱ្យ កងទ័ព យួនកុម្មុយនិស្ត វាយ កាត់កាប់បាន ទឹកដីខ្មែរ ១ ភាគ ៣ ក្នុងរយៈពេល តែ ពីរ បីថ្ងៃ តែប៉ុណ្ណោះ។ បន្ទាប់មក កងទ័ព

---

លេខ៦ : ការពារខេត្ត ក្រចេះ, មណ្ឌលគីរី។ មាន ទីបញ្ជាការសឹក នៅ ទីក្រុង ក្រចេះ។
នៅឆ្នាំ ១៩៧៣ អគ្គបញ្ជាការដ្ឋានខ្ពស់ នៃ កងទ័ពជាតិ បានបង្កើត បន្ថែម ភូមិភាគ ពិសេស ៣ ទៀត : ភ្នំពេញ, ដំបន់ ទន្លេមេកុង និង អនុដំបន់ តាកែវ។

[4] កងទ័ពជើងគោក មាន ៣០ កងវរសេនាតូច, ១៥ កងអនុសេនាធំ គាំទ្រ ក្នុងវិស័យ យកការណ៍, ដឹងជញ្ជូន, វិស្វកម្ម, ១ កងកាំភ្លើងបាញ់យន្តហោះ, ១ កងវរសេនាធំ កង្វៀល (un régiment de reconnaissance), ១ ក្រុមកាំភ្លើងធំ និង ១ ក្រុមវេជ្ជសាស្ត្រ។ កងទ័ពអាកាស មានចំនួន បុគ្គលិក ១២៥០ រួមទាំង អាកាសយានិក, វិស្វករ, ការិវិទ្យុ, យន្តការី និង អ្នកបច្ចេកទេសអាកាសចរណ៍។ កងទ័ពជើងទឹក មាន បុគ្គលិក យោធា ចំនួន ប្រមាណ ១០០០ នាក់។

នោះ រុលចូល មកក្នុង ស្រុកស្អាង ដែល មាន ចម្ងាយ ប្រមាណ តែ ៣០ គីឡូម៉ែត្រ ពី ទីក្រុងភ្នំពេញ ហើយ រៀបចំ វាយយក រាជធានី តែម្តង ដែល ជា គោលដៅ ចុងក្រោយ របស់គេ ដើម្បី ឱ្យត្រូវនឹង ពាក្យសន្យា របស់ លោក ជូ អេង ឡាយ (រដ្ឋមន្ត្រីទី១ ចិន) និង ផាំ វ៉ាន់ ដុង (រដ្ឋមន្ត្រីទី១ យួនខាងជើង), នៅពេល ជួប សម្តេច សីហនុ នៅ ទីក្រុងប៉េកាំង បន្ទាប់ពី សហសភាជាតិខ្មែរ បានទម្លាក់ព្រះអង្គ ពីដំណែង ប្រមុខរដ្ឋ, ថា កងទ័ពយួនកុម្មុយនិស្ត នឹងវាយយកអំណាច មកថ្វាយព្រះអង្គ វិញក្នុង រយៈពេល តែមួយ សប្តាហ៍ ប៉ុណ្ណោះ។ ។ ដូច្នេះ សមរភូមិ (bataille) នៅ ស្រុកស្អាង[5] ជា ការតស៊ូ ដាច់ខាត នៃ កងទ័ពជាតិខ្មែរ ដើម្បី ការពារ រាជធានី និង អាយុជីវិត នៃ របបថ្មី ផង។ ដើម្បី កុំឱ្យ សាច់រឿង (scénario) នេះ អាចនឹងកើតឡើងបាន, កងទ័ពជាតិខ្មែរ បានលាតទ័ព វាយប្រឆាំងខ្លាំង ដោយ ប្រមូលផ្តុំ ៦ កងវរសេនាតូច, ៤ កងជីវពល (ចំនួន រេហ៍ពល ៣.៥០០ នាក់), កាំភ្លើងធំ ទំហំ ៧៥ មម ៤ ដើម បែបជំនាន់ សង្គ្រាមលោកលើកទី១, រថក្រោះ ចំណាស់ ៣ គ្រឿង ដែល ទ័ពបារាំង គេទុកឱ្យ និង យន្តហោះ សំរាប់ សាលា ប្រភេទ ‹‹CESNA›› ១គ្រឿង។ កងទ័ពនោះ ដឹកនាំដោយ លោក ឧត្តមសេនីយត្រី ស៊ូស្តែន ហ្វែណង់ ដែស លើក ទៅច្បាំងនឹងខ្លាំង អស់រយៈពេល ៤ អហោរត្ត[6]។ វាយ

---

5 ស្រុកស្អាង មាន អាណិកជន យួន រស់នៅ ច្រើនណាស់ នៅសម័យនោះ។

6 អហោរត្ត : ថ្ងៃយប់។

# ដំណោះស្រាយ យោធា ?

ដេញ សត្រូវ ចេញពី ទីប្រជុំជន ស្រុកស្អាង បាន។ នេះ ជា ជ័យជំនះ លើកទី១ តាំងពី ទ័ពយួនកុម្មុយនិស្ត ចាប់ផ្តើម វាយប្រហារ ទ័ពជាតិខ្មែរ តែ ទុក ជា ជោគជ័យ ដ៏សំខាន់ណាស់ លើផ្លូវចិត្ត នៃ យុទ្ធជនខ្មែរ ដែល បាន ប្តេជ្ញា ការពារ បូរណភាពទឹកដីជាតិ។ ការវាយប្រហារ នៃ កងទ័ពយួន កុម្មុយនិស្ត ប្រកបដោយ មហិទ្ធានុភាព នៃ កម្លាំងអាវុធសឹកទំនើប ត្រូវបាន គទប់ទទឹងបាន ដោយ កងទ័ពជាតិ នៅខែ មិថុនា ឆ្នាំ ១៩៧០, ប៉ុន្តែ ទឹកដីខ្មែរ ២⁄៣ ក្លាយ ជា សមរភូមិ នាំឱ្យ ភាន់ប្រែ ជីវិត រស់នៅ របស់ ប្រជាពលរដ្ឋ។ សង្គ្រាមនេះ គឺ យួនកុម្មុយនិស្ត ជា អ្នកបង្កើត បង្ខំឱ្យ រដ្ឋាភិបាល ស្រោចស្រង់ជាតិ តបវិញ ដោយ គ្មានជម្រើស ព្រោះ គ្រប់ការប៉ុនប៉ង រក ដំណោះស្រាយ តាម សន្តិវិធី ត្រូវបាន ពួកឈ្លានពាននោះ ច្រានចោល ដោយគ្មាន ពន្យល់ ហេតុផល នោះឡើយ។ ទន្ទឹករណ៍ តែមួយគត់ ដែល ពួកនោះ លើកឡើង គឺៈ ពួកគេ មាន សិទ្ធិ បោះទ័ព នៅ ស្រុកខ្មែរ ដោយ មាន ការអនុញ្ញាត ពី សម្តេច សីហនុ។

## ដំណោះស្រាយ តាម ផ្លូវយោធា ?

ដំណោះស្រាយនោះ វា ជា សិទ្ធិការពារខ្លួន, ពុំមែន ជា ជម្រើស នោះឡើយ។ ដូច្នេះ សាធារណរដ្ឋខ្មែរ ត្រូវការ ជំនួយ យោធា ពីសំណាក់ ប្រទេស ជា មិត្ត ដើម្បី ប្រឈរមុខ នឹង ការវាយប្រហារ ដោយ បំពាន ច្បាប់អន្តរជាតិ និង អធិបតេយ្យភាពខ្មែរ ពីសំណាក់ កងទ័ពយួនកុម្មុយនិស្ត។ សហរដ្ឋអាមេរិក មាន ការ

## ដំណោះស្រាយ យោធា ?

យឺតពេលច្រើន រហូត ៣ សប្តាហ[7] (២៧ ថ្ងៃ) ទើប ឆ្លើយ យល់ព្រមនឹង សំណើរនេះ។ ក្នុងរយៈពេលនោះ, កងទ័ពជាតិ វាយទប់ទល់ ជាមួយ មធ្យោបាយសឹក អត្តខាត់ ទាំង ធនធានមនុស្ស និង សម្ភារៈយោធា បើប្រៀបបៀបធៀបនឹង សត្រូវ របស់ខ្លួន។ ចំណែក កងទ័ពយួនកុម្មុយនិស្ត វិញ បើក ការវាយប្រហារឈមមុខ ជំហម[8] ជ័យជំនះ ព្រោះ មាន ជំនឿជាក់ច្បាស់ ថា តែមួយ សប្តាហ នឹងវាយឈ្នះ ជា ពុំខាន ដូច ដែល ជូ អេង ឡាយ និង ផាំ វ៉ាន់ ដុង បាន សន្យានឹង សម្តេច សីហនុ។ តែ រយៈពេលនោះ យុវជន និង ប្រជាពលរដ្ឋខ្មែរ ស្ម័គ្រចិត្ត ចូល ប្រយុទ្ធ ក្នុងសង្គ្រាម ការពារជាតិ ប្រកបដោយ ទឹកចិត្ត មិនព្រមចាញ់សត្រូវ ទោះបីដឹងថា គូប្រយុទ្ធ មាន ការពិសោធ ធ្វើ សង្គ្រាមយូរឆ្នាំមកហើយ ក៏ដោយ។ ខេមរៈយុវជននោះ ដែល ក្លាយជាទាហាន ដោយ ភាពស្និតជាប់ ក្នុងស្មារតី តែ ២៤ ម៉ោង នាំគ្នាទៅច្បាំង ដោយ សម្រិត ទឹកចិត្ត ជា អ្នកការពារជាតិ ហើយបាន បូជាជីវិត ច្រើនក្រៃ នៅលើ សមរភូមិ។ តែ ពលកម្ម ដ៏មហិមានោះ ក៏វា អាចសម្រេញ ចិត្តខ្លាំង ជា ចោរ ឈ្លានពាន ភ្លើនចិត្ត នៅចំពោះមុខ ការតស៊ូខ្មែរ ជា យុត្តៈ (juste) ដែល តម្អឹង[9] មិនព្រមចាញ់។ តែនៅ ថ្ងៃ ទី៣០ មេសា កងពលធំ អាកាស

[7] កងទ័ពយួនកុម្មុយនិស្ត ចាប់ផ្តើមវាយ ពី ថ្ងៃទី ២៧ មីនា ១៩៧០, រីឯសហរដ្ឋអាមេរិក វិញ សម្រេចចិត្តជួយ ជា សម្ភារៈយោធា ដឹកមកដល់ស្រុកខ្មែរ នៅ ថ្ងៃ ទី ២៣ មេសា។

[8] ជំហម :កិ. ឈមមុខទៅរក។

[9] តម្អឹង : គុ. រឹងទទឹង។

ចល័ត លេខ១ (1ère division aéromobile) អាមេរិកាំង និង កងទ័ពយួន ខាងត្បូង រុករានចូល មកក្នុង ដំបន់ ចំពុះទា ក្នុង ទឹកដីខ្មែរ ដោយ គ្មាន ជូនដំណឹង ដល់ រដ្ឋាភិបាលខ្មែរ ជា មុន ក្នុង គោល ដៅ ស្វែងរក មូលដ្ឋានសឹក និង អគ្គបញ្ជាការ យៀកកុង ដើម្បី កំទិចចោល។ ប្រតិបត្តិការសឹក អាមេរិកាំងនោះ គេ ដាក់ កំហិត ចម្ងាយ រុកចូល តែ ៣០ គីឡូម៉ែត្រ ពី ព្រំដែន យួនខាង ត្បូង និង រយៈពេល តែ ២ ខែ យ៉ាងយូរ។ ទង្វើនេះ ធ្វើឱ្យ រដ្ឋាភិ បាលខ្មែរ ស្រងាកចិត្ត ហើយ តម្រូវ ធ្វើ ការតវ៉ា ជា ផ្លូវការ ជា គោលការណ៍ នឹង អន្តរាគមន៍ យោធានេះ ក្នុងឋានៈ ជា អ្នក ពឹងគេ។ សំនួរ សួរ ថាៈ តើ ប្រតិបត្តិការសឹកនោះ ជា ជំនួយ កាត់បន្ថយ នូវ ការវាយប្រហារ កងទ័ពយួនកុម្មុយនិស្ត មកលើ កងទ័ពខ្មែរ ? វា មាន យោបល់ ប្រឆាំងគ្នា នៅក្នុង មជ្ឈដ្ឋាន នយៈជន[10] និង យោធិនខ្មែរ។ អ្នកខ្លះ យល់ឃើញថា វា ជា អំណោយផល ព្រោះ ជា ការព្រមាន ដល់ យួនកុម្មុយនិស្ត និង ចិនប្រជាមានិត ថា សហរដ្ឋអាមេរិក ច្បាស់ជា មិនទុកឱ្យ យួន កុម្មុយនិស្ត ឈ្លានពាន ស្រុកខ្មែរ តាម ទំនើងចិត្តនោះឡើយ។ អ្នកខ្លះទៀត យល់ឃើញថា អាមេរិកាំង អនុញ្ញាតឱ្យ កងទ័ព យួនខាងត្បូង រុកចូល មកក្នុងទឹកដីខ្មែរ ជា ទង្វើមួយ នាំឱ្យ សាធារណរដ្ឋខ្មែរ មាន ការពិបាក នឹង ពន្យល់ ដល់ យុវជន និង ពលរដ្ឋខ្មែរ ថា កងទ័ព យួនកុម្មុយនិស្ត និង យួនខាងត្បូង ចូលមកក្នុងស្រុកខ្មែរ វា មាន លក្ខណៈ ខុសគ្នា។ ចំពោះ ខ្មែរ

10 នយៈជន : អ្នកនយោបាយ។

# ដំណោះស្រាយ យោធា ?

តែងតែ មាន អារម្មណ៍ ថា យួន គឺតែមួយ ហើយជា សត្រូវ តពូជនឹងខ្មែរ។ ការពិត ប្រតិបត្តិការសឹកនោះ វា មាន រូបភាពជា យុទ្ធសាស្ត្រ របស់ អាមេរិកាំង សំរាប់ បំរើ អត្ថប្រយោជន៍ សង្គ្រាម នៅ យៀកណាម តែប៉ុណ្ណោះ, រីឯ ស្រុកខ្មែរ វិញ ចំពោះ អាមេរិកាំង អ្វី ដែល កំពុងកើតឡើង វា ជា ការទទួលខុសត្រូវផ្ទាល់ របស់ខ្មែរ ព្រោះ សង្គ្រាម នៅ ស្រុកខ្មែរ វា មិនបានគ្រោងទុក នៅក្នុង យុទ្ធសាស្ត្រ របស់ លោក ប្រធានាធិបតី អាមេរិកាំង រីឆាត និច សុន (Richard Nixon) ដើម្បី បញ្ចប់ សង្គ្រាម នៅ យៀកណាម នោះឡើយ។ មួយវិញទៀត ជោគជ័យ ដ៏សំខាន់ របស់ អាមេរិកាំង នៅ ស្រុកខ្មែរ អាចនឹងបង្ខំ យួនខាងជើង ឱ្យវិលត្រឡប់ មករក តុ ចរចា ឡើងវិញ នៅ ទីក្រុងប៉ារីស ដែល វាមិនទៅមុខសោះ អស់រយៈពេល ២ឆ្នាំ មកហើយ។

ពិតណាស់ហើយ ថា សហរដ្ឋអាមេរិក សម្រេច ជួយ ជំនួយយោធា និង សេដ្ឋកិច្ច ដល់ សាធារណរដ្ឋខ្មែរ តែ ចំនួន វា មិនឆ្លើយស្របនឹង បញ្ហាធ្ងន់ធ្ងរ ដែល ខ្មែរ កំពុង ជួបប្រទះ។ ប៉ុន្តែគេ អាចនិយាយ បញ្ឈឺចិត្ត ដល់ ពួកអ្នកដឹកនាំ នៃ សាធារណរដ្ឋខ្មែរ ថាៈ ការណ៍នេះ វា ជា កម្មវិបាក ដែល ពួកខ្លួន ចង់ លេងនឹងភ្លើង, វា តែងតែ រលាក ដូច្នោះឯង។ ចំពោះ យួនខាងជើងគេ ទុក ស្រុកខ្មែរ ជា មូលដ្ឋាន សេដ្ឋកិច្ច និង យោធា សំខាន់សំរាប់ ធ្វើសង្គ្រាម នៅ យៀកណាមខាងត្បូង។ គោលដៅ គឺជ័យជំនះយោធា ដាច់ខាត លើ យៀកណាមខាងត្បូង។ ដូច្នេះយួនខាងជើង រង់ចាំតែ កងទ័ព អាមេរិកាំង ចាកចេញ ពី

យៀកណាមខាងត្បូង[11] ដើម្បី បើក ការវាយប្រហារ ដ៏វិសាល មកលើ កងទ័ព យួនខាងត្បូង។ មែនទែន ការចរចា នៃ កិច្ច ព្រមព្រៀង សន្តិភាព ជាមួយ សហរដ្ឋអាមេរិក វា គ្រាន់តែ ជា កលយុទ្ធមួយ រង់ចាំ ថ្ងៃ តែប៉ុណ្ណោះ។ រីឯ សហរដ្ឋអាមេរិក វិញ, វា គ្រាន់តែជា ការស្វែងរក កិត្តិយស ក្នុង ការបោះបង់ សមរភូមិ ដែល ខ្លួន ជា សឹកចារីថែម ក្នុងនាម ជា អ្នកការពារ សេរីភាព និង លិទ្ធិប្រជាធិបតេយ្យ។ ដូច្នេះឯង សង្គ្រាម ផ្ទុះឡើង នៅ ស្រុកខ្មែរ វា កើតឡើងផ្ទុយស្រឡះ ពី នយោបាយ នៃ ការដក ខ្លួន ចេញ ពី សង្គ្រាម នៅ យៀកណាម របស់ លោក រីឆាត និច សុន និង ស្របនឹង គោលបំណង នៃ យួនកុម្មុយនិស្ត ក្នុង ការ ពង្រីក សមរភូមិ នៅ ឥណ្ឌូចិន។ នៅពេលនោះ អាមេរិកាំង មិនសូវ កង្វល់ អំពី ដើមហេតុ នៃ សង្គ្រាម ដោយ ទុក ស្រុកខ្មែរ ជា អ្នករងគ្រោះ នោះឡើយ, ផ្ទុយទៅវិញ ការឈ្លានពាន នៃ យួន កុម្មុយនិស្ត វា គ្រាន់តែ ជា អត្ថសញ្ញា[12] (paramètre) ថ្មីមួយ សំរាប់ សហរដ្ឋអាមេរិក យកមក ដោះស្រាយ ជាមួយ យួនខាងជើង អំពី ការដកខ្លួន ចេញពី យៀកណាម។ ដូច្នេះ គេ អាចទុកបាន ថា សង្គ្រាម នៅស្រុកខ្មែរ នៅពេលនោះ វា ជា លាភជ័យ របស់

11 នៅឆ្នាំ ១៩៧០ វេហ៏ពល អាមេរិកាំង នៅ យៀកណាមខាងត្បូង នៅ សល់ តែ ៣២០.០០០ នាក់។ ហើយ ចំនួននេះ នឹងត្រូវ ដកចេញ បន្ត បន្ទាប់ទៀត ១៥០.០០០ នាក់ រហូត ដល់កំរិតសូន្យ។
12 អត្ថសញ្ញា : ការកំណត់។

អាមេរិកាំង និង យួនខាងជើង ផង។ សួរ ថា តើ សម្ដេច សីហនុ ឬ លោក លន់ នល់ ជា មនុស្ស ឆោតល្ងង់ ?

អន្តរាគមន៍យោធា មានកំរិត និង ឆ្លង របស់ អាមេរិកាំង មកក្នុង ទឹកដីខ្មែរ ដូច្នឹង វា ពិត ជា អំណោយផល ផ្លូវចិត្ត និង ជាប្រការ អវិជ្ជមាន ផង សំរាប់ខ្មែរ ព្រោះ វា ហាក់បី ដូចជា ការអនុញ្ញាត ឱ្យ កងទ័ព យួនកុម្មុយនិស្ត បន្ត វាយប្រហារ បានដោយសេរី មកលើ កងទ័ពខ្មែរ ចម្ងាយលើស ពី ៣០ គីឡូម៉ែត្រ ពី ព្រំដែន យួនខាងត្បូង។ ក្នុង រយះពេល ២ ខែ ដែល អាមេរិកាំង កំរិតទុកនោះ កងទ័ពយួនកុម្មុយនិស្ត បាន ពង្រីក សមរភូមិ ស្ទើរ តែពាសពេញ នៅក្នុង ទឹកដីខ្មែរ ជាពិសេស កាន់ផ្ដាច់ផ្លូវជាតិ ភ្នំពេញ-កំពង់សោម ជា ផ្លូវ អាយុជីវិតខ្មែរ។ ចំពោះ កងទ័ពយួន កុម្មុយនិស្ត នៅពេលនោះ វា គ្រាន់តែ ដកថយចេញពី បរិវេណ ដែល អាមេរិកាំង គ្រោយទុកនោះ មួយរយះសិន វា នឹងបានសុខ ទៅហើយ ព្រោះ គេ មាន ជំនឿ ថា អនាគតកាល គឺ ជា កម្មសិទ្ធ ផ្ដាច់មុខ របស់គេ បន្ទាប់ ពី កងទ័ព អាមេរិកាំង ដកខ្លួន ចេញ ពី ស្រុកយួនខាងត្បូង។

សំនួរមួយទៀត សួរថា តើ សហរដ្ឋអាមេរិក មានជំនឿ ថា សាធារណរដ្ឋខ្មែរ នឹងអាចប្រឈមមុខ នឹងការវាយប្រហារ ដ៏សាហាវ ពីសំណាក់ កងទ័ព យួនកុម្មុយនិស្ត បានដែរឬទេ ? មិនពិតប្រាកដ ថា ជឿនោះឡើយ បើ ធ្វើការប្រៀបធៀប នៃគុណ្យការ នៃ កម្លាំងទ័ព នៃ គូប្រយុទ្ធ, ដូច្នោះឯង ដែល អាមេរិ

# ដំណោះស្រាយ យោធា ?

កាំង ចាំមើល លទ្ធភាព ផ្លូវចិត្ត នៃ កងទ័ពជាតិខ្មែរ និង គោលចំណង់មុត របស់ របប នយោបាយថ្មី មុននឹងជួយខ្មែរ។ ចំណែក ពួក ឧត្តមសេនីយ យួនខាងត្បូង គេ គ្មានជំនឿ សោះ នោះឡើយ រហូត មាន ឧត្តមសេនីយខ្លះ ដូច លោក ដូ កៅ ទ្រី ប្រាប់ អាមេរិកាំង ត្រង់ៗ ថា គួរឱ្យ កងទ័ព យួនខាងត្បូង ចូល កាន់កាប់ ស្រុកខ្មែរ ឱ្យបានមុន យួនខាងជើង ពុំនោះសោត ស្រុកខ្មែរ នឹងក្លាយ ជា មូលដ្ឋានសឹក កុម្មុយនិស្ត ដែល វា នឹង គំរាម ដល់ យៀកណាមខាងត្បូង។ ចរិយា អាមេរិកាំង ដែល លើកយកមក បង្ហាញ ខាងលើនេះ, ក៏នាំឱ្យ ពួកអ្នកដឹកនាំ សាធារណរដ្ឋខ្មែរ គិត ថា ៈ ខ្មែរ ត្រូវពឹងលើ កម្លាំងខ្លួនឯង ជា បឋម ព្រោះ សង្គ្រាមនេះ វា មាន ស្នាម នៅក្នុង ប្រវត្តិសាស្ត្រ ជាតិខ្មែរ គឺ មហិច្ឆិតា ទឹកដី របស់ យួន, ដូច្នេះ សង្គ្រាម ដែល កើតឡើងនោះ វា មិនមែន ជា ការចៃដន្យ នោះដែរ ព្រោះ ទឹក ដីខ្មែរ វា ជា សត្វចំណី (proie) នៅក្នុង ស្មារតី របស់ ពួកអ្នកដឹកនាំ យួន ជា និច្ច។ ប៉ុន្តែ សម្ដេច សីហនុ ព្រះអង្គ មាន ការស្រមើ ស្រមៃ ថា យួនកុម្មុយនិស្ត នឹងជួយ ព្រះអង្គ ដើម្បី យកអំណាច មកថ្វាយ ព្រះអង្គវិញ។ សេចក្ដីភាន់ នៅក្នុង គំនិត ផ្ដាប់មុខ នេះឯង ដែលជា វិនាដកម្ម របស់ ប្រជាជាតិខ្មែរ រហូត មកដល់ សព្វថ្ងៃ។ ចំណែក ពួកខ្មែរក្រហម វិញ មាន ជំនឿ ថា បក្ស កុម្មុយនិស្តចិន នឹងជួយខ្លួន ក្នុង ការធ្វើបដិវត្ត ផ្ដាច់ឬស (radical) ដោយ ភ្លេចគិត ថា នៅលើ ទឹកដីខ្មែរ កងទ័ព យួនកុម្មុយនិស្ត ជា ម្ចាស់ ដាច់មុខ ដោយ មាន ការសមគំនិត ពី សហភាព សូ

វៀត។ ទោះបី ចិនប្រជាមានិត កៀងគរ សហរដ្ឋអាមេរិក ថា ខ្លួន ជា ម្ចាស់ នៃ ពួកខ្មែរក្រហម និង គាំរាមផង ថា អាមេរិកាំង ជា អ្នក ទទួលខុសត្រូវ លើ កម្មវិបាក នៃ ការបើក សមរភូមិថ្មី នៅ ស្រុកខ្មែរ ព្រោះ ប្រជាជនចិន ៧០០ លាន នាក់ ច្បាស់ជា នៅពីក្រោយ ការតស៊ូ របស់ ប្រជាជនខ្មែរ។ តែ ការប្រកាសនោះ ចិន ភ្លេចគិតថា នៅ លើ សមរភូមិ ខ្មែរ និង លាវ គឺ យួន ជា ម្ចាស់ការ ដាច់មុខ។ តាម ការពិត ពួកខ្មែរក្រហម, គាំទ្រ ដោយ ចិន, អាចរស់បាន ដោយសារយួន ឱ្យរស់ មិនមែន ចិន នោះឡើយ។ ដូចយ៉ាង នៅឆ្នាំ ១៩៧៩ របប ខ្មែរក្រហម ត្រូវបាន កងទ័ពយួន វាយកំទិចចោល ក្នុង រយះពេល តែ ២ សប្តាហ៍ តែប៉ុណ្ណោះ។ គេ អាច សួរថា តើ នៅឯណាទៅ ប្រជាជនចិន ៧០០ លាននាក់ នៅពីក្រោយ កម្ពុជា ប្រជាធិបតេយ្យ ?

## កម្លាំង កងទ័ព យៀកកុង និង យួនខាងជើង

កងទ័ព យៀកកុង និង យួនខាងជើង បានមក បោះទ័ព នៅ ក្នុង ទឹកដីខ្មែរ ដោយមាន ការសមគំនិត ពី សម្តេច សីហនុ។ កងទ័ពនោះ មាន :

- កងពលធំ លេខ១ : RCT-101-D មាន ចំនួន រេហ៍ពល ២.០០០ នាក់, បោះទ័ព នៅ ស្រុក មង្គលបូរី ក្នុង ខេត្ត តាកែវ;
- កងពលធំ លេខ ៥ : RQTS-05 et 275 មាន រេហ៍ពល ចំនួន ៥.០០០ នាក់, បោះទ័ព នៅ ស្រុកស្នួល ក្នុង ខេត្ត ក្រចេះ;

- កងពលធំ លេខ៧: RQTS-141-165 et 209 មាន វរេហ៏ពល ចំនួន ៦.២០០ នាក់, បោះទ័ព នៅ ស្រុក មេមុត ក្នុង ខេត្ត កំពង់ចាម;
- កងពលធំ លេខ៩: RQTS-C-271 et 272 មាន វរេហ៏ពល ចំនួន ២.០០០ នាក់, បោះទ័ព នៅ ស្រុកជប់ ក្នុង ខេត្ត កំពង់ចាម;
- វណសិរ្ស B-3: RQTS-24-28-40-66-95-0 មាន វរេហ៏ពល ចំនួន ១០.៨០០ នាក់, បោះទ័ព ស្រុក បរកែវ ក្នុង ខេត្ត រតនគីរី;
- បូកនឹង ទីបញ្ជាការ និង ទីសេនាធិការ ទាំងឡាយ: មាន បុគ្គលិក យោធា និង ស៊ីវិល ចំនួន ១២.០០០ នាក់ និង សេវាកម្មដឹកជញ្ជូន មាន ចំនួន បុគ្គលិក យោធា និង ស៊ីវិល ២៣.០០០ នាក់, ដូច្នេះ ចំនួន សរុប ទាំងអស់ មាន ៦៥.០០០ នាក់[13]។

នៅថ្ងៃ ទី ២៩ មីនា ឆ្នាំ ១៩៧០ កងទ័ពនោះឯង បាន លាតទ័ព វាយប្រហារ កងទ័ពជាតិខ្មែរ ដោយ មាន ការអនុញ្ញាត ពី សម្តេច សីហនុ។ ព្រះកិរិយានោះ គឺ ព្រះអង្គ ជ្រើសរើសយក សត្រូវជាតិ រាប់ពាន់ឆ្នាំ ប្រឆាំងនឹង ប្រជាជាតិខ្លួនឯង។ ជម្រើសបែបនោះឯង ដែល របប សាធារណរដ្ឋខ្មែរ លើកយកមក បង្ហាញ នូវ អំពើ ក្បត់ជាតិ របស់ព្រះអង្គ ដែល វា ធ្វើ ឱ្យកាន់តែស្រអាប់ នៃ របបរាជានិយម។ តែ នៅចំពោះមុខ ស្ថានការណ៍

13 Mémoire d’une guerre oubliée par le Général Sosthène Fernandez. Edition AsieInfo Publishing.

## ដំណោះស្រាយ យោធា ?

នេះ តម្រូវឱ្យ កងទ័ពជាតិខ្មែរ មិនញញើត នឹងវាយតបវិញ ដោយ សេចក្ដីក្លៀវក្លា ព្រោះជា ករណីយកិច្ច ជាសភាវគតិ នៃ ការការពារ ជាតិ។ ដូច្នេះ នៅពេលនោះ កូនខ្មែរម្នាក់ៗ មិន ចាំបាច់ មាន សេចក្ដីក្លាហាន ព្រោះ នៅក្នុង សកម្មប្រតិកម្ម រៀងៗខ្លួន នៅ ចំពោះមុខ ការឈ្លានពាននោះ ភារៈជ្រៅ ជា កូនខ្មែរ វាបង្កើត នូវ គុណភាព ជាស័ក្តិសិទ្ធិ[14]នោះ រួចស្រេចតែ ម្ដង។

បន្ទាប់មក នៅថ្ងៃ ៣០ មេសា កងទ័ពយៀកកុង ដកចេញ ពី ដំបន់ ‹‹ផ្លែសន្ទូច›› និង ខេត្តរតនគីរី ដើម្បី គេច ពី ការវាយ ប្រហារ នៃ កងទ័ព អាមេរិកាំង និង យួនខាងត្បូង ហើយ នាំ គ្នា ជ្រាតចូល មកក្នុង ខេត្ត បាត់ដំបង និង សៀមរាម។ នៅ ថ្ងៃ ទី៦ មិថុនា កងទ័ពយៀកកុង វាយ ចូលកាន់កាប់ ប្រសាទ អង្គរវត្ត យកធ្វើជា ជម្រង នៃ ទីបញ្ជាការសឹក ដោយ ជឿជាក់ ច្បាស់ ថា កងទ័ពជាតិខ្មែរ មិនវាយចូលឡើយ ព្រោះ ជា បូជនីយដ្ឋាន។ ការរកឃើញ អាវុធយុទ្ធភ័ណ្ឌ ច្រើនក្រៃ របស់ កងទ័ព យៀកកុង លាក់ទុក នៅក្នុង ទឹកដីខ្មែរ បញ្ជាក់ ថា យៀកណាម ខាងជើង និង យៀកកុង យក ទឹកដីខ្មែរ ដើម្បី រៀបចំ ការវាយ លុក លើ យួនខាងត្បូង នៅពេល ដែល កងទ័ព អាមេរិកាំង ដកថយ ចេញពី សង្គ្រាម នៅ យៀកណាម ដែល កាន់តែ មាន រូបភាព សាហាវ និង អប្រជាប្រិយភាព លើ ឆាកអន្តរជាតិ និង

14 ស័ក្តិសិទ្ធិ : គុ. ដែលមានអំណាច, ដែលវិសេសវិសាល។

## ដំណោះស្រាយ យោធា ?

លើកឆាកជាតិ អាមេរិកាំង។ នៅឆ្នាំ ១៩៧២ ថ្ងៃ ទី១ ឧសភា មាន ផ្ទុះគ្រាប់បែក នៅក្នុង ទីបន្ទោរបង់ នៃ មន្ទីរ បញ្ចកោណ (Pentagone) នៅ សហរដ្ឋអាមេរិក ដែល ជា ស្នាដៃ នៃ ចលនា « Weathermen » ប្រឆាំងនឹង សង្គ្រាម នៅ វៀតណាម។ នៅថ្ងៃ ទី៤ ឧសភា ឆ្មាំជាតិ (garde nationale) នៃ រដ្ឋ Kent (Kent State) បានបាញ់ ទៅលើ បាតុករ ជា និស្សិត នៃ មហាវិទ្យាល័យ នៅទីក្រុង Ohio, ធ្វើបាតុកម្ម ប្រឆាំងនឹង អន្តរាគមន៍ អាមេរិកាំង នៅ ស្រុកខ្មែរ, នាំឱ្យមាន ស្លាប់ ៤នាក់ និង របួស ៩នាក់។ ព្រឹត្តការណ៍ នោះឯង ដែលនាំឱ្យ លោក ប្រធានាធិតី រីឆាត និច សុន ស្រូតរូត ធ្វើ អភិក្រម នៃ ដំណោះស្រាយ តាម សន្តិវិធី នៃ សង្គ្រាម នៅ វៀតណាម។ នៅក្នុង ដំណើរការនោះ សហរដ្ឋអាមេរិក មាន ចេតនា នឹងប្រគល់ វាសនា នៃ ស្រុកខ្មែរ ឱ្យទៅ ចិនកុម្មុយនិស្ត ជា អ្នករាប់រង រក ដំណោះស្រាយ នៃ ជម្លោះ អាវុធ រវាង សាធារណរដ្ឋខ្មែរ នឹង រាជរដ្ឋាភិបាល បង្រួបបង្រួមជាតិ និរទេស នៅ ទីក្រុង ប៉េកាំង។ យុទ្ធសាស្ត្រនេះ បញ្ជាក់ឱ្យឃើញថា សហរដ្ឋអាមេរិក មើលស្រាល លើ មូលហេតុ នៃ សង្គ្រាម នៅ ស្រុកខ្មែរ ដែល ជា សង្គ្រាម ការពារ បូរណភាព ទឹកដី ប្រឆាំងនឹង ការឈ្លានពាន ពីសំណាក់ កងទ័ព យួនកុម្មុយនិស្ត។ ហើយ នៅចំពោះមុខ ការឈ្លានពាននេះ កងទ័ពជាតិខ្មែរ អាចវាយតប ទុបទល់បាន ដើម្បី អាយុជីវិត នៃ សាធារណរដ្ឋខ្មែរ ដ៏ក្មេងខ្ចី និង អធិបតេយ្យភាព នៃ ប្រជាជាតិខ្មែរផង។

## យុទ្ធសាស្ត្រយោធា នៃ សាធារណរដ្ឋខ្មែរ

នៅពេលនោះ, ការពារ សាធារណរដ្ឋខ្មែរ គឺ ចាំបាច់ ត្រូវ ការពារ រដ្ឋធានី ក្រុងភ្នំពេញ ជា អាទិភាព ដាច់ខាត ដែល កងទ័ព យួនកុម្មុយនិស្ត មាន យុទ្ធសាស្ត្រ នឹងវាយ យកឱ្យបាន ដាច់ខាតដែរ ព្រោះ អ្នកណា កាន់កាប់ ទីក្រុងភ្នំពេញ គឺ ជា អ្នក ដឹកនាំ កម្ពុជា។ ការការពារ ទីក្រុងភ្នំពេញ ត្រូវចាំបាច់ ការពារ ផ្លូវ ទំនាក់ទំនង រវាង រាជធានី នឹង ខេត្តពីរ នៅខាងជើង (បាត់ដំបង, សៀមរាប), ខាងលិច (កំពង់ធំ), កំពង់ផែ កំពង់សោម និង ខេត្តទាំងឡាយ ខាងត្បូង ជាប់នឹង ព្រំដែន យៀកណាម ខាងត្បូង ព្រោះ ចំណង អាកាសចរណ៍ ជាមួយ ប្រទេសជាមិត្ត និង ផ្លូវទឹក នៃ ទន្លេមេកុង ភ្ជាប់ ភ្នំពេញ នឹង យៀកណាម ខាងត្បូង វា មិនអាចទុក ជា ផ្លូវធំទោល សំរាប់ ផ្គត់ផ្គង់ នូវ សេចក្តីត្រូវការ ជា អាយុជីវិត នៃ ប្រជាពលរដ្ឋខ្មែរ និង យោធា បាននោះឡើយ។ តែ ការការពារ ជាចិរកាល ប្រកបដោយ ប្រសិទ្ធភាព នៃ ផ្លូវ ជា អាយុជិវិតនោះ វា ត្រូវការ មធ្យោបាយ ជាច្រើន ទាំង ធនធាន មនុស្ស និង សម្ភារៈយោធា ដែល គ្រប់ កងទ័ព នៅលើ ពិភពលោក តែងតែ ជួបប្រទះនឹង ការលំបាក។ តែនៅពេលនោះ លោក ឧត្តមសេនីយ សាក់ ស៊ុតសាខន[15] ជា អគ្គនាយសេនាធិការ រង នៃ កងទ័ពជាតិ ជាមួយ លោក

---

15 សាក់ ស៊ុតសាខន សិស្សនាយទាហាន ជំនាន់ទី១ លោក បាន សិក្សា នៅ សាលាយោធា នៅ ប្រទេសបារាំង គ្រប់ ថ្នាក់សិក្សា តាំង ពី សាលាការអនុវត្តន៍, នាយសេនាធិការ និង សង្គ្រាម។

# ដំណោះស្រាយ យោធា ?

លន់ នល់ សម្រេច ប្រើ យុទ្ធសាស្ត្រ ផ្សេងមួយទៀត គឺ បើក ប្រតិបត្តិសឹកធំ វាយប្រហារ កម្លាំងទ័ពខ្មាំង ដើម្បី រំលាយ កំហិត (contrainte) ខ្មាំង ចោល។ តែ បើ ពិចារណា លើ សក្តានុពល នៃ កងទ័ពជាតិ និង ការពិសោធ នៅ ពេលនោះ នៅ ចំពោះ មុខ កម្លាំង វិភូ[16] របស់ សត្រូវ, វិធី បែបនេះ វា ឆាប់ពេក ព្រោះ កងទ័ពជាតិ មិនទាន់ត្រៀមខ្លួនជាស្រេច នៅឡើយ។ ប្រតិបត្តិការសឹក ចេនឡា ទី១[17] (ពីខែ កញ្ញា ឆ្នាំ ១៩៧០ ដល់ខែ កុម្ភៈ ឆ្នាំ ១៩៧១) នៅពេលនោះ សត្រូវ ស្ទង់មើល កម្លាំង និង យុទ្ធសាស្ត្រ នៃ កងទ័ពជាតិ ដោយ ជៀសវាង មិនវាយតប ជា ទ្រង់ទ្រាយធំ ដែលនាំឱ្យ លោក លន់ នល់ មាន ជំនឿ ថា ជា មហាជោគជ័យ ព្រោះ កងទ័ពជាតិ បានវាយ រំដោះបាន ស្រុក តាំងគោក, បារាយណ៍។ ដូច្នេះ នៅឆ្នាំ ១៩៧១ ខែ កញ្ញា លោក លន់ នល់ បន្ត ប្រតិបត្តិសឹក ដាក់ឈ្មោះថា ចេនឡា ទី២ ប្រើ យុទ្ធសាស្ត្រ ដូច បេះបិទនឹង ចេនឡា ទី១។ លើកទី២នោះ សត្រូវ ស្គាល់ យុទ្ធសាស្ត្រ, ដូច្នេះ វា ធ្វើជា បើកផ្លូវ ឱ្យកងទ័ពជាតិ ប្រមូលកម្លាំង ជា អតិបរមា រុលចូល ហូរហែ តាម ផ្លូវជាតិ លេខ៦ រហូតដល់ ភ្នំសន្ទុក, បន្ទាប់មក វា វាយ ផ្តាច់ បីកង់ រួចហើយ នៅក្នុង ១កង់ៗ វា វាយសម្រុក ដោយ កម្លាំងអគ្គិ (puissance de feu) ហលាហល នាំឱ្យ

---

16 វិភូ : គុ. ដែលជាធំក្រៃលែង, ខ្លាំងពូកែ។

17 ចេនឡា ទី១ និង ទី២ ជា ប្រតិបត្តិការសឹក បើកផ្លូវជាតិ លេខ៦ ពី ភ្នំពេញ ទៅ កំពង់ធំ ដើម្បី រក្សា ផ្លូវ ទំនាក់ទំនង សេដ្ឋកិច្ច រស់នៅជាប្រក្រតី (économie de subsistance) ព្រោះ ខេត្តកំពង់ធំ ជា ជង្រុកស្រូវធំមួយ របស់ ស្រុកខ្មែរ។

បែកខ្ចាត់ខ្ចាយ កងទ័ពជាតិ មាន ស្លាប់ យោធា រាប់រយនាក់ និង ខូចខាត សម្ភារៈយោធា ១/៣ របស់ កងទ័ពជាតិ។ ចេនឡា ទី២ ជា បរាជ័យទាំងអស់[18] និង ឮខ្ទរខ្ទារ លើ ឆាក អន្តរជាតិ និង ជាតិ[19]។ ជោគជ័យ របស់ កងទ័ពយួនកុម្មុយនិស្តនោះ នាំឱ្យវា ប្រមើល ជាថ្មី នឹងវាយ ទីក្រុងភ្នំពេញ។ ដូច្នេះ យៀកកុង យក កងពលតូច ១ កង មកបោះនៅ ភ្នំបាសិត នៅក្នុង ខេត្តកំពក់ស្ពឺ មាន ចម្ងាយ ប្រមាណ ២៥ គីឡូម៉ែត្រ ពី ទីក្រុងភ្នំពេញ។ តែ ការប៉ុនប៉ងនោះ ត្រូវបាន កងទ័ពជាតិ វាយ ក្នុង រយៈពេល មួយ សប្តាហ៍ ឡើងកាន់កាប់ ភ្នំនោះបាន។ យៀកកុង ដកថយ ពី សមរភូមិ ដោយ បោះបង់ចោល សព ទាហាន និង សម្ភារៈយោធា ជាច្រើន[20] នៅនឹងកន្លែង។ បរាជ័យ ពីរដង, លើកទី១ នៅ ស្រុកស្អាង និង នៅ ភ្នំបាសិត នៅចំពោះមុខ កងទ័ពជាតិ នាំឱ្យ យួនកុម្មុយនិស្ត បោះបង់ គោលបំណង វាយ ទល់មុខ (attaque frontale) យក ទីក្រុងភ្នំពេញ។

អគ្គមេបញ្ជាការថ្មី[21] នៃ កងទ័ពជាតិខ្មែរ ជ្រើសរើស យក យុទ្ធសាស្ត្រ នៃ ការការពារ ជាមួយ ចំនួន រេហ៍ពល កើតឡើង ពី

---

18 កងទ័ពជាតិខ្មែរ បាតបង់ ២ កងពលតូច (ស្លាប់ និង របួស)។

19 ប្រតិបត្តិការសឹក ចេនឡា ចុះផ្សាយ នៅ ខែ មីនា ២០១៨ នៅ ក្នុង ប្លុក របស់ខ្ញុំ។

20 មេបញ្ជាការសឹក របស់កងទ័ពជាតិ គឺ លោក ឧត្តមសេនីយ ស៊ូស្តែន ហ្វៃណង់ដែស។

21 លោក លន់ នល់ បាន តែងតាំង លោក ឧត្តមសេនីយ ស៊ូស្តែន ហ្វៃណង់ដែស ជា អគ្គនាយមេបញ្ជាការ និង អគ្គនាយសេនាធិការ នៃ កងទ័ពជាតិ ជំនួសលោក បន្ទាប់ ពី បរាជ័យ ប្រតិបត្តិការសឹក ចេនឡាទី២។

២៥.០០០ ដល់ ២៥០.០០០ នាក់។ នៅពេលនោះ ត្រូវប្រឈមមុខ នឹង កងទ័ព យៀកកុង និង យួនខាងជើង ដែល កាន់តែ ជ្រាតចូល មកក្នុងទឹកដីខ្មែរ កាន់តែច្រើនឡើង។ មួយវិញទៀត យួនកុម្មុយនិស្ត ប្រើ យុទ្ធសាស្ត្រ ធ្វើ សង្គ្រាម ដុតបំផ្លាញ ជនបទ ដើម្បី ឱ្យ អស់កសិករ មិនអាច ធ្វើ ស្រែ ចិញ្ចឹមជីវិតបាន ហើយ នាំគ្នា ភៀសខ្លួន មកក្នុង ដំបន់ កាន់កាប់ ដោយ កងទ័ពជាតិ ដើម្បី បង្កើតឱ្យមាន បញ្ហាសេដ្ឋកិច្ច រស់នៅជាប្រក្រតី ដល់ រដ្ឋាភិបាលខ្មែរ ដែល ត្រូវមាន ករណីយកិច្ច ចិញ្ចឹម ប្រជាពលរដ្ឋ។ កលយុទ្ធនេះ គឺ សំរាប់ ធ្វើ សង្គ្រាម នៃ ការឃោសនា អាចធ្វើ ការបំផ្លើស ការប្រឌិត  អាចបង្កើត ពាក្យ ចចាមអារាម នៅ ក្នុង ចំណោម ជនភៀសខ្លួន ដែល មាន ភ្នាក់ងារ កុម្មុយនិស្ត លាក់ខ្លួន សំរាប់ និយាយ អាក្រក់ ពី សាធារណរដ្ឋខ្មែរ។

## សង្គ្រាមចិត្តសាស្ត្រ និង មនោគមវិជ្ជា

ទ្រឹស្តីមូលដ្ឋាន សង្គ្រាម ចិត្តសាស្ត្រ និង មនោគមវិជ្ជា គឺ មុខងារ នៃ គំនិត។ បើ គំនិត គ្មានមុខងារ សង្គ្រាមនោះ ពិត ជាគ្មានន័យ។

ពួកយួនកុម្មុយនិស្ត ធ្វើសង្គ្រាម ចិត្តសាស្ត្រ វាយប្រហារ ភាពស្រួយ នៃ សាធារណរដ្ឋខ្មែរ នៅក្នុង ស្ថានភាព ដ៏សែនពិបាក ដូចយ៉ាង ទាហាន មាន ប្រាក់ខែតិច, ប្រជាជាន កាត់តែ ក្ររហាម, អំពើ ពុករលួយ ជាទូទៅ ដែល សុទ្ធ ជាចំណុច ជាក់ស្តែង នាំឱ្យ សត្រូវ លើកយកមក ឃោសនា ថា រដ្ឋាភិបាល គ្មាន

សមត្ថភាព ដោះស្រាយ បញ្ហា សង្គម និង សង្គ្រាម។ សង្គ្រាមចិត្តសាស្ត្រនោះ គឺ ធ្វើ ក្នុងគោលដៅ បំបែក ប្រជាជន ពី រដ្ឋាភិបាល ហើយ បន្ទាប់មកទៀត ធ្វើឱ្យ អ្នកទាំងពីរនេះ ក្លាយ ជាសត្រូវនឹងគ្នាតែម្តង ដែល យួនកុម្មុយនិស្ត គេ ឱ្យឈ្មោះថា ផែនការកលល្បិច ឱ្យ ‹‹ដៃ ស្តាំ សត្រូវ វៃ ដៃ ឆ្វេង ខ្លួនឯង និង ក៏ដូចជាផ្ទុយទៅវិញ (vice-versa)››។ កលយុទ្ធនេះ ពួកចិនកុម្មុយនិស្ត ធ្លាប់ប្រើ នៅពេល សង្គ្រាម ជាមួយ ពួកចិនជាតិនិយម នៅ ទស្សវត្សរ៍ ៤០។ ពួកកុម្មុយនិស្ត ធ្វើសង្គ្រាម ពុំមាន គោលដៅ ស្វែងរក សន្តិភាព នោះឡើយ ព្រោះ ពាក្យនេះ វា គ្មាន នៅក្នុង វាក្យសព្ទ នៃ បដិវត្តន៍ កុម្មុយនិស្ត នោះឡើយ។ ក្នុងករណីខ្លះ បើ ពួកកុម្មុយនិស្ត គេ យក ពាក្យ សន្តិភាព មក ប្រើ ក៏មិនយល់ ដូច ពួកអ្នកប្រជាធិបតេយ្យ នោះដែរ ព្រោះ សន្តិភាព គឺ គ្រាន់តែ ជា ការបន្ត សង្គ្រាម តាម មធ្យោបាយ ផ្សេងមួយទៀត។ នៅពេល ធ្វើ សង្គ្រាមអាវុធ ពួកកុម្មុយនិស្ត ប្រើ ដៃស្តាំ សំរាប់ វាយ កងទ័ពសត្រូវ រីឯ ដៃឆ្វេង ទាក់ទាញ ទឹកចិត្ត ប្រជាជន ឱ្យស្អប់ កងទ័ពសត្រូវ។ ហើយ នៅពេលនោះឯង ដែលសត្រូវ ត្រូវប្រើ ដៃស្តាំខ្លួន សំរាប់ វាយទប់ទល់ គូសត្រូវអាវុធរបស់ខ្លួន និង ដៃឆ្វេង គិតតែពី រងនឹងការស្អប់ខ្ពើម នៃ ប្រជាជន ផង។ ដូច្នេះ ដៃទាំងពីរ មិនបានយកមកប្រើរួម ដើម្បី វាយគូសត្រូវនោះឡើយ។ កលយុទ្ធនេះ, ពួកយួន កុម្មុយនិស្ត យកមកប្រើ នៅស្រុកខ្មែរ ប្រកបដោយ ជោគជ័យ ព្រោះ ដៃស្តាំ នៃសាធារណរដ្ឋខ្មែរ រវល់ វាយតបនឹង កងទ័ព យួនកុម្មុយនិស្ត រីឯ

ដៃឆ្វេង វិញ ត្រូវ វាយទប់នឹងខ្មែរគ្នាឯង គឺ ពួកខ្មែរក្រហម និង ពួកសីហនុនិយម ដែល នាំគ្នា ជួយ សត្រូវជាតិ ប្រឆាំងនឹង ប្រជាជាតិខ្លួនឯង, បន្ថែមពីលើនេះ គឺ រងនឹង បាតុកម្ម នៃ យុវជន និង ការទាមទារ នៃ សិទ្ធិរស់នៅ របស់ ប្រជាជន ដែល ជាជនរងគ្រោះនឹង សង្គ្រាមផង ដែលពួកយួនកុម្មុយនិស្តជា ចារី។

នៅពេលណា ដែល ទាហាន គ្រប់ ថ្នាក់ មាន ការសង្ស័យ ទៅលើ បេសកកម្ម ចម្បង របស់ខ្លួន គឺ វាយប្រហារ សត្រូវជាតិ និង កំទិច វាចោល គឺ នៅពេលនោះឯង សត្រូវ នឹងមានជ័យជំនះ ជាពុំខាន។ សកម្មភាព ចិត្តសាស្ត្រនោះ គឺ យួនកុម្មុយនិស្ត គេ បញ្ចូល ភ្នាក់ងារ របស់គេ មកក្នុង កងទ័ពជាតិ ធ្វើវិទ្ធង្សនា ទាញ កូនទាហាន ឱ្យស្អប់ មេទាហាន, មេទាហាន ឱ្យលែង ទុកចិត្ត លើ បទបញ្ជា ថ្នាក់លើ ព្រោះ យល់ឃើញ ថា លំដាប់ស័ក្ដិ ជា វណ្ណៈ, វិន័យ ជា អំណាចផ្ដាច់ការ និង គោលដៅ នៃ សង្គ្រាម គឺ សំរាប់តែ បំរើ ផលប្រយោជន៍ ពួកអ្នកធំ, ដូច្នេះ ត្រូវ ឈប់ស្ដាប់ គ្រប់ ខ្សែចង្វាក់ នៃ បញ្ជាការ (chaîne de commandement)។

នៅក្នុង ជួរ យុវជន, ភ្នាក់ងារ យួនកុម្មុយនិស្ត គេ ប្រើ វិធី យកតម្លៃ នៃ លទ្ធិប្រជាធិបតេយ្យ របស់ សាធារណរដ្ឋខ្មែរ សំរាប់ បង្កើត អនាធិបតេយ្យ។ គេ ធ្វើវិទ្ធសង្សនា ឱ្យ ក្រុមសិស្សានុសិស្ស, និស្សិត និង គ្រូបង្រៀន ឱ្យមាន ចិត្តរវាត[22] ពីហេតុផលពិត នៃ សង្គ្រាម ដែល មាន ដើមចម ជា ការការពារ

22 រវាត : គុ. ឃ្លាត។

## ជំនោរះស្រាយ យោធា ?

បូរណភាពទឹកដី ឱ្យវា ក្រឡាស់ ទៅជា ការបំរើ ផលប្រយោជន៍ សហរដ្ឋអាមេរិក នៅក្នុង សង្គ្រាម នៅ យៀកណាម ទៅវិញ។ បន្តិចម្តងៗ ផ្នែកមួយ នៃ ក្រុមទាំងឡាយនោះ មាន ចិត្តមិច្ឆា[23] ក៏ក្លាយ ដោយមិនដឹងខ្លួន ទៅជា ដៃឆ្វេង ប្រដាប់ អាវុធ អរូប របស់ យួនកុម្មុយនិស្ត សំរាប់ វាយ សាធារណរដ្ឋខ្មែរ នាំធ្វើឱ្យខូច សេចក្តីទុកចិត្ត រវាង រដ្ឋាភិបាល នឹង យុវជន តែម្តង។ យ៉ាង ណាមិញ ក៏មាន យុវជន កុះករ ចូលបំរើកងទ័ពជាតិ និង យុវ បញ្ញាវន្ត ប្រដាប់ចិត្ត ស្នេហាជាតិ ស្ម័គ្រ ចូលប្រយុទ្ធ ក្នុង វិស័យ គំនិត ប្រឆាំងដាច់ខាតនឹង លទ្ធិកុម្មុយនិស្ត យួន-ចិន និយម ដែល ជា សត្រូវ នឹង ព្រះពុទ្ធសាសនា និង សន្តិភាព។ ការស្ម័គ្រ ចិត្តទាំងអស់ នោះឯង ដែល បង្កើតបាន ជា របង ការពារជាតិ នៅក្នុង ស្មារតី នៃ ការក្រាញ (résistance) នៅចំពោះមុខ សង្គ្រាម ឈ្លានពាន និង លទ្ធិកុម្មុយនិស្ត ដែល ជា ទស្សនៈវិជ្ជា ឃោរឃៅ និង ជា របប ដឹកនាំ ផ្តាច់ការ មាន គោលដៅចម គឺ ប្តូរ សង្គម តាម ការធ្វើបដិវត្ត វណ្ណៈ ហិង្សា។ ការក្រាញនោះ គឺ ជា រូបភាព ពិត នៃ ការតស៊ូ ប្រកបដោយ ភាពក្លាហាន និង ភាពក្លៀវក្លា របស់ យុវជន ប្រឆាំងនឹងសត្រូវជាតិ។ បើគ្មាន ការតស៊ូនោះ គឺ ច្បាស់ជា យួនកុម្មុយនិស្ត វាយ រលំ សាធារណរដ្ឋខ្មែរ តែ ១ សប្តាហ៍ តែប៉ុណ្ណោះ ដូច លោក ជូ អេង ឡាយ និង ផាំ វ៉ាន់ ដុង បាន

[23] មិច្ឆា : គុ. ដែលគិតខុស។

សន្យា ជាមួយ សម្ដេច សីហនុ ថា នឹងវាយ កងទ័ពជាតិខ្មែរ យក អំណាច មកថ្វាយ ព្រះអង្គវិញ។

## គោលជំហរ របស់ សហរដ្ឋអាមេរិក

សេចក្ដីសង្ឃឹម របស់ ប្រជាពលរដ្ឋខ្មែរ គឺ មាន នៅក្នុង សុន្ទរកថា បំភ្លឺផ្លូវ របស លោក ប្រធានាធិបតី រីឆាត និចសុន ធ្វើនៅថ្ងៃ ទី ៣០ មេសា ឆ្នាំ ១៩៧០ នៅក្នុងនោះ លោក បង្ហាញ អំពី គោលជំហរ របស់ សហរដ្ឋអាមេរិក ប្រឆាំងនឹង ការពង្វាត ឥទ្ធិពល នៃ លទ្ធិកុម្មុយនិស្ត នៅក្នុង ពិភពលោក ហើយ នៅ ពេលថ្មីនេះ វា ជ្រាបចូលមក ក្នុងទឹកដីខ្មែរ ដែល ជា ប្រទេស ទន់ខ្សោយមួយ។ សហរដ្ឋអាមេរិក ត្រូវតែ សួរខ្លួនឯង នូវ សំណួរ ថា តើ ខ្លួន ជា ប្រទេស មហទ្ធន[24] និង ខ្លាំងបំផុត នៅក្នុង ប្រវត្តិសាស្ត្រ នៃ មនុស្សជាតិ អាចនឹង មាន លក្ខណៈ ចាំបាច់ សំរាប់ ហ៊ានតស៊ូ ប្រឈរមុខ ផ្ទាល់ នឹង ក្រុមមួយ ដែល ប្រានចោល នូវ ការខំប្រឹងប្រែង គ្រប់បែបយ៉ាង ដើម្បី ស្វែងរក សន្តិភាព សមតាម សមធម៌, មិនរវល់ ដល់ ការព្រមាន អាមេរិកាំង ណាមួយឡើយ, ជាន់ឈ្លី នូវ គ្រប់ កិច្ចព្រមព្រៀង ដ៏ឧឡារិក, បំពាបំពាន អព្យាក្រឹតភាព នៃ ប្រទេស គ្មានអាវុធ ការពារ ខ្លួន និង យក អ្នកទោសសង្គ្រាម អាមេរិកាំង ធ្វើ ចំណាត់ខ្មាំង (Sic)។ ប៉ុន្តែ សុន្ទរកថា បំភ្លឺផ្លូវ និង ជា សេចក្ដីសង្ឃឹមនោះ វា ក៏ ជា កាំបិត មុខពីរ សំរាប់ ស្រុកខ្មែរ ផងដែរ ពីព្រោះ សាធារណ

[24] មហទ្ធន : គុ. ដែលមានទ្រព្យច្រើន។

រដ្ឋខ្មែរ ត្រូវសម្លប[25]ខ្លួន តាម បំណង នៃ ដំណោះស្រាយ ចង់ បាន របស់ សហរដ្ឋអាមេរិក ជាមួយ យួន និង ចិន កុម្មុយនិស្ត ដែល ជា ដំណោះស្រាយ ស្វែងរក សន្តិភាព ពិត តែ ជា សន្តិភាព សំរាប់ តែ ការពារ កិត្តិយស របស់ សហរដ្ឋអាមេរិក តែប៉ុណ្ណោះ។ នៅក្នុង ដំណោះស្រាយនោះ ជា បឋម សហរដ្ឋអាមេរិក សម្រេច ឈប់ ផ្តល់ ជំនួយយោធា[26] ដល់ សាធារណរដ្ឋខ្មែរ ដោយ មិនរវល់ គិតថា ទង្វើនេះ នឹងធ្វើ ឱ្យបាត់ សមតា នៃ កម្លាំង យោធា នៅលើ សមរភូមិ និង មាន អនុភាព ផ្លូវចិត្ត ជា មហន្តរាយ ដល់ អស់ជនខ្មែរ ជា អ្នកស្នេហាជាតិ និយម លទ្ធិប្រជាធិបតេយ្យ ដែល កំពុង តស៊ូនឹង យួនឈ្លានពាន និង លទ្ធិកុម្មុយនិស្ត។ កិច្ចព្រមព្រៀង សន្តិភាព ថ្ងៃ ទី២៧ មករា ឆ្នាំ ១៩៧៣ រវាង សហរដ្ឋអាមេរិក ជាមួយ យួនខាងជើង នៅក្នុងនោះ ទុក លទ្ធភាព ឱ្យ ពួកខ្មែរក្រហម ដែល មាន យួន និង ចិន កុម្មុយនិស្ត ជា អ្នកគាំពារ អាច បដិសេធ បាន ដែល វា នាំឱ្យ កងទ័ពយួន កុម្មុយនិស្ត, ជាគោលការណ៍ ត្រូវ ដកទ័ព ចេញ ពី ស្រុកខ្មែរ, បែរ ជា អាច រក្សា នឹង បញ្ចូល បន្ថែម រេហ៍ពល និង រថក្រោះ រាប់

---

25 សម្លប : កិ. ឱ្យស្របចូល។

26 ជំនួយ យោធា ផ្តល់ឱ្យ កងទ័ពជាតិខ្មែរ ត្រូវបាន បញ្ចប់ នៅ ដើម ឆ្នាំ ១៩៧៣។ ជា ទូទៅ កងទ័ពជាតិ មាន ការគាំទ្រ ពី កងទ័ពអាកាស អាមេរិកាំង តិចតួចណាស់ គឺ អាច សុំបាន លុះត្រា តែ នៅក្នុង ការជួបប្រទះ នូវ ការលំបាក ខ្លាំងណាស់។ ការទម្លាក់ គ្រាប់បែក នៅ ស្រុកខ្មែរ គឺ ធ្វើឡើង នៅក្នុង យុទ្ធសាស្ត្រ នៃ សង្គ្រាម របស់ អាមេរិកាំង នៅ យៀកណាម តាំងពីឆ្នាំ ១៩៦៩ មកម្លេះ តែ ជាការទម្លាក់ ទៅលើ ទីតាំង យោធា នៃ កងទ័ព យៀកកុង និង យួនខាងជើង នៅលើ ទឹកដីខ្មែរ។

រយគ្រឿង មកក្នុង ស្រុកខ្មែរ[27] ដោយ មាន ការសមគំនិត ពី ពួកខ្មែរក្រហម។ ពិតណាស់ហើយ ថា វា មាន ទំនាស់ ជារឿយៗ រវាង កងឯកភាព ខ្មែរក្រហម នឹង យួនកុម្មុយនិស្ត នៅលើ សមរភូមិ មួយចំនួន តែថា គ្រប់ថ្នាក់ បញ្ជាការ នៃ ពួកខ្មែរក្រហម វិញ វា ត្រូវធ្វើឱ្យស្របនឹង យុទ្ធសាស្ត្រ និង កលយុទ្ធ របស់ ពួកយួនកុម្មុយនិស្ត ព្រោះ ពួកនោះ ជា អ្នកដឹកនាំ សង្គ្រាម នៅ ស្រុកខ្មែរ។

បន្ទាប់ពី ការចុះហត្ថលេខា កិច្ចព្រមព្រៀង សន្តិភាព នៅឆ្នាំ ១៩៧៣, យួនកុម្មុយនិស្ត ធ្វើ ខេមរយានកម្ម នៃ សង្គ្រាម នៅ ស្រុកខ្មែរ ដើម្បី បំភាន់ ដល់ មតិ អន្តរជាតិ ថា ជា សង្គ្រាម រវាង ខ្មែរ នឹង ខ្មែរ ព្រោះ កងទ័ពយួន ដកចេញពីស្រុកខ្មែរ ស្រប តាម ការអនុលោម នៃ កិច្ចព្រមព្រៀង សន្តិភាព, តែ នៅលើ សមរភូមិ វិញ កងទ័ព យួនកុម្មុយនិស្ត រួមបញ្ចូល ខ្លែងខ្លួន ជា ខ្មែរ ក្នុង កងឯកភាព ខ្មែរក្រហម ហើយ ប្រើ យុទ្ធសាស្ត្រ រំព័ទ្ធ ទីតាំង យោធា របស់ កងទ័ពជាតិ គ្រប់ទីកន្លែង កុំឱ្យ មាន លទ្ធភាព ធ្វើ ចលនាទ័ពបាន និង វាយកាត់ផ្តាច់ ផ្លូវជាតិ និង ផ្លូវទឹក ទន្លេមេកុង ជា អាយុជីវិត ដើម្បី ឱ្យ ពួកខ្មែរក្រហម ប្រមូលផ្តុំកម្លាំង របស់វា ដើម្បី វាយប្រហារ រដ្ឋធានី ភ្នំពេញ។ ដូច្នោះឯង យួនខាងជើង និង ចិនប្រជាមានិត បានបំពា

---

27 កងពលធំ លេខ៩ នៃ យួនកុម្មុយនិស្ត នៅតែស្ថិតនៅក្នុង ខេត្ត ស្វាយរៀង និង កងពល លេខ១ នៅក្នុង ខេត្ត តាកែវ និង កំពង់ចាម ទោះជា មាន កិច្ចព្រមព្រៀង សន្តិភាព ក៏ដោយ។

បំពាន ភ្លាមៗ កិច្ចព្រមព្រៀង សន្តិភាព នៅ យៀកណាម ខាងត្បូង នៅ ស្រុកខ្មែរ ផង។ ពិតណាស់ហើយ ការបំពាននោះ ដែលនាំឱ្យ លោក ប្រធានាធិបតី រីឆាត និចសុន សម្រេចចិត្ត ឆ្លើយតប ដោយ អនុញ្ញាត ឱ្យកងទ័ព អាកាស អាមេរិកាំង ធ្វើការទម្លាក់គ្រាប់បែកជា ថ្មី នៅ យួនខាងជើង។ តែ ជា អកុសល លោក ត្រូវបាន សហសភា អាមេរិកាំង បង្ខំ ឱ្យ លាលែងពីដំណែង នៅ ថ្ងៃ ទី៨ សីហា ឆ្នាំ ១៩៧៤[28]។ ទង្វើនោះ ជា ការបាត់នៃ រដ្ឋបុរស នៃ លោកសេរី ម្នាក់ ដែល អាច ពត់ ពួកកុម្មុយនិស្តបាន។ ហើយ ជា ភ័ព្វអាក្រក់ ដល់ ស្រុកខ្មែរ និង ស្រុកយួនខាងត្បូង ដែល ជ្រើសរើស ជំរុំ នៃ សេរីភាព ប្រឆាំងនឹង ជំរុំ កុម្មុយនិស្ត ហើយ ត្រូវ ជុំរុំ ជា មិត្ត និង អ្នកទី៣[29] លែងទុក ពួកកុម្មុយនិស្ត ជា សត្រូវនឹង សេរីភាព ដោយ មាន ជំនឿ ថា ពួកនោះនឹងគោរព កិច្ចព្រមព្រៀង សន្តិភាព ពិតប្រាកដ។ ការណ៍នេះជា ការស្រមើស្រមៃ ពិឃាត ដល់ ប្រជាជន ស្រឡាញ់ សេរីភាពនិង លទ្ធិប្រជាធិបតេយ្យ។

តែទោះបី គ្មាន ជំនួយយោធា តែ កងទ័ពជាតិ អាចវាយទប់ការវាយលុក ទីក្រុងភ្នំពេញ ពីសំណាក់ កងទ័ព កុម្មុយនិស្ត(យួន និង ខ្មែរក្រហម) នៅឆ្នាំ ១៩៧៤, ធ្វើឱ្យ ខ្មាំង ទទួល បរាជ័យ តែ ក្រុងឧដុង្គ មាន ចម្ងាយ ៣៥ គីឡូម៉ែត្រ ពី ទីក្រុង

---

28 លោក មាន បញ្ហា ច្បាប់ ក្នុង រដ្ឋកិច្ច Watergate។

29 អ្នកទី៣ : អ្នកដែលប្រឆាំងនឹងយើងផង ហើយសត្រូវផង និង អ្នកដែលមិនប្រឆាំងនឹងយើង ហើយក៏មិនប្រឆាំងនឹងសត្រូវដែរ។

ភ្នំពេញ ត្រូវបាន ពួកកុម្មុយនិស្ត វាយ យកបាន។ នៅពេលនោះ លើឆាក អន្តរជាតិ រាជរដ្ឋាភិបាល បង្រួបបង្រួមជាតិខ្មែរ ដឹកនាំដោយ សម្តេច សីហនុ ទទួល បរាជ័យ ជាថ្មី ព្រោះ មហាសន្និបាត នៃ អ.ស.ប. បានបោះឆ្នោត មិនទទួលស្គាល់ ជាតំណាង នៃ ប្រទេសកម្ពុជា។ ការណ៍ទាំងឡាយនោះ នាំឱ្យ ពួកកុម្មុយនិស្ត ប្តូរ យុទ្ធសាស្ត្រ ដោយ ប្លោង គ្រាប់ រ៉ូកែត ១២២ និង កាំភ្លើងធំ មកលើ ទីក្រុងភ្នំពេញ នាំឱ្យស្លាប់ ប្រជាជន ស៊ីវិល ជា ច្រើន។ យុទ្ធសាស្ត្រ ថ្មីនេះ គឺ សំរាប់ ធ្វើឱ្យ ទឹកចិត្ត អ្នកភ្នំពេញ ធ្លាក់ចុះ ហើយ នាំគ្នារិះគន់ កងទ័ពជាតិ និង រដ្ឋាភិបាល ថា គ្មាន សមត្ថភាព ការពារ ប្រជាពលរដ្ឋ។ មើលឃើញថា សាធារណរដ្ឋខ្មែរ លែងមាន ប្រជាប្រិយភាពហើយ និង អ្នកភ្នំពេញ ធ្លាក់ទឹកចិត្ត, នៅឆ្នាំ ១៩៧៥ ពួកកុម្មុយនិស្ត ផ្តើម វាយប្រហារ ជាថ្មី ទីក្រុងភ្នំពេញ ដោយ ប្រើ កលយុទ្ធថ្មី គឺ ប្រើផែនការកលល្បិច ប្រយុទ្ធ ដូច កងទ័ព សូវៀត វាយ ចូល ទីក្រុងស្តាលីនក្រាត (Stalingrad) នៅពេល សង្គ្រាមលោក លើកទី២។ ពួកកុម្មុយនិស្ត រៀបចំ ជា ៣ ជួរ វាយលុកៈ ជួរ ទី១ មាន យោធាប្រដាប់អាវុធ B40 និង B41 វាយសម្រុក ខ្សែ ការពារ របស់ កងទ័ពជាតិ ជា បេសកកម្ម ធ្វើអត្តឃាត ដ្បិត មិនអាច ដកខ្លួនថយក្រោយបាននោះឡើយ  ព្រោះ នៅពីក្រោយ មាន ជួរ ទី២ សំរាប់ បាញ់ ប្រហារ យោធា ណា ដែល មិនព្រម សម្រុក ទៅមុខ ឬរត់ ថយក្រោយ។ ជួរ ទី៣ ជា មូលដ្ឋាន ប្លោង គ្រាប់ កាំភ្លើងត្បាល់ ១២២ មម, ៨០ មម, កាំភ្លើងធំ ១០៥ មម, ៨២ មម និង

## ដំណោះស្រាយ យោធា ?

រ៉ូកែត ១០៧ និង ១២២ មម។ ជួរ ទី៣ នេះ គឺ នៅក្រោមបញ្ជាការ ផ្ទាល់ របស់ ពួកយួនកុម្មុយនិស្ត។ កលយុទ្ធ អមនុស្សធម៌ នេះ វា ផ្តល់ នូវ លទ្ធផលល្អ ក្នុង ផ្នែកយោធា ព្រោះ ពួកកុម្មុយនិស្ត វាយ បែក ទីតាំង នៃ កងទ័ពជាតិ មួយចំនួន ហើយ ធ្វើឱ្យ ស្លាប់ ទាហានជាតិ ក្នុង មួយថ្ងៃ ពី ៨៥ ទៅ ១០០ នាក់ និង របួស ពី ២៥០ ទៅ ៣៥០ នាក់។ វា ជា ការវាយប្រហារបង្ហូរឈាម ដ៏សាហាវ ម្តងហើយម្តងទៀត តែ កងទ័ពជាតិ អាចទប់ទល់បាន ដោយគ្មានការចុះខ្សោយ នោះឡើយ។ ប៉ុន្តែ ដើម្បី ប្រឈរមុខនឹង ការវាយប្រហារ រន្ទាន់ បែបនេះ កងទ័ពជាតិ ត្រូវការ ធនធាន មនុស្ស បន្ថែម និង គ្រាប់រំសេវ ផង ព្រោះ កងទ័ពជាតិ មិនអាចច្បាំងនឹង កាំភ្លោះ និង ទ័ព បីសាច ដូចជំនាន់ លោកតា ឃ្លាំងមឿង នោះបានឡើយ។ សេចក្តីត្រូវការនោះ វា អាស្រ័យ ទៅលើ ជម្រើស នយោបាយ នៃ រដ្ឋាភិបាលខ្មែរ និង ជំនួយយោធា អាមេរិកាំង។ ដូច្នេះ ដំណោះស្រាយ យោធា របស់ សាធារណរដ្ឋខ្មែរ វា អាចមានកើតបាន គឺ វា អាស្រ័យ ទៅលើ អត្ថសញ្ញា ទាំងពីរនោះឯង។

បញ្ហានេះ ខ្ញុំ នឹងយកមករៀបរាប់ នៅពេលក្រោយទៀត នៅក្នុង អត្ថបទមួយទៀត ដែល មាន ចំណងជើង ថា ‹‹ដំណោះស្រាយ នយោបាយ ?››៕